# សលាកប័ត្រព័ត៌មាន ៖ តំបន់សេដ្ឋកិច្ចពិសេស និងសិទ្ធិមនុស្សនៅកម្ពុជា

**ទិដ្ឋភាពរួម** ៖ ក្នុងទសវត្សរ៍កន្លងមកនេះ តំបន់សេដ្ឋកិច្ចពិសេសបានរីកចម្រើនគួរឲ្យកត់សម្គាល់នៅកម្ពុជា និងនៅជុំវិញតំបន់។ ខណៈដែលអត្ថប្រយោជន៍ នៃតំបន់សេដ្ឋកិច្ចពិសេស បាននាំមកនូវលក្ខខណ្ឌក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងការធ្វើពាណិជ្ជកម្មក៏ពិតមែន ប៉ុន្តែការអភិវឌ្ឍនិងប្រតិបត្តិការរបស់តំបន់សេដ្ឋកិច្ចពិសេសទាំងនោះតែងជាប់ពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សដូចជាការដកហូតយកដីធ្លី បញ្ហាលក្ខខណ្ឌការងារ ឬការប៉ះពាល់ដល់បរិស្ថានជាដើម។ សលាកប័ត្រព័ត៌មាននេះបានគូសបញ្ជាក់ពីច្បាប់នានាដែលជាមូលដ្ឋាននៃការបង្កើត និងត្រួតពិនិត្យតំបន់សេដ្ឋកិច្ចពិសេស រួមនឹងចំណុចព្រួយបារម្ភទាក់ទងនឹងសិទ្ធិមនុស្ស និងផ្តល់អនុសាសន៍ជាក់លាក់ ដើម្បីធានាថាការអភិវឌ្ឍសេដ្ឋកិច្ចដើរទន្ទឹមគ្នានឹងការគោរពសិទ្ធិនិងសេរីភាពជាមូលដ្ឋាន។

## សេចក្តីផ្តើម

ក្នុងប៉ុន្មានទសវត្សរ៍នេះ ប្រទេសកម្ពុជាបានឆ្លងកាត់ការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ ក្នុងឆ្នាំ២០០៥ រាជរដ្ឋាភិបាលកម្ពុជាបានផ្តួចផ្តើមអោយមានតំបន់សេដ្ឋកិច្ចពិសេសក្នុងប្រទេស ជាផ្នែកមួយនៃគោលនយោបាយ វិនិយោគដោយមានគោលដៅ «បង្កបរិយាកាសឱ្យកាន់តែប្រសើរឡើងដើម្បីបង្កើនផលិតកម្ម ភាពប្រកួតប្រជែង កំណើនសេដ្ឋកិច្ចជាតិ ជម្រុញការនាំចេញ និងការបង្កើតការងារជូនប្រជាជន»។[1] គិតត្រឹមឆ្នាំ២០១៣ ដោយយោងទៅតាមប្រភពផ្លូវការបានបង្ហាញថា មានតំបន់សេដ្ឋកិច្ចពិសេសចំនួន ៣០ នៅក្នុងប្រទេសកម្ពុជា ក្នុងនោះ មាន ៩ កន្លែង បានប្រតិបត្តិការ ៤ កំពុងដំណើរការសាងសង់ ៧ កំពុងដំណើរការ និង១០មានឈ្មោះនៅក្នុងបញ្ជី តែអសកម្ម។[2] យោងតាមគេហទំព័ររបស់អង្គការទិន្នន័យអំពីការអភិវឌ្ឍនៅកម្ពុជា ដែលបានតាមដានស្រាវជ្រាវអំពីតំបន់សេដ្ឋកិច្ចពិសេសនៅទូទាំងអាស៊ីអាគ្នេយ៍ បានបង្ហាញថាកម្ពុជាមានតំបន់សេដ្ឋកិច្ចពិសេសចំនួន ៣៨ គិតត្រឹមឆ្នាំ២០១៦។[3]

---

[1] អនុក្រឹត្យលេខ១៤៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា https://opendevelopmentcambodia.net/km/dataset/?id=sub-decree-no-147-on-the-organization-and-functioning-of-the-council-for-development-of-cambodia&search_query=P3M9Q291bmNpbCtmb3IrRGV2ZWxvcG1lbnQrb2YrQ2FtYm9kaWEmdHlwZT1sYXdzX3JlY29yZCZwYWdlPTA=# (អនុក្រឹត្យលេខ ១៤៧),អនុក្រឹត្យលេខ ១៤៨ ស្តីពីការបង្កើត និងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស, មាត្រា១១ https://opendevelopmentcambodia.net/km/dataset/?id=sub-decree-on-organization-and-management-of-special-economic-zone&search_query=P3M9c3BlY2lhbCtlY29ub21pYyt6b25lJnR5cGU9bGF3c19yZWNvcmQmcGFnZT0w (អនុក្រឹត្យលេខ ១៤៨), អនុក្រឹត្យលេខ ១៤៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា https://opendevelopmentcambodia.net/km/dataset/?id=sub-decree-no149-on-the-organization-and-functioning-of-the-council-for-development-of-cambodia&search_query=P3M9Q291bmNpbCtmb3IrRGV2ZWxvcG1lbnQrb2YrQ2FtYm9kaWEmdHlwZT1sYXdzX3JlY29yZCZwYWdlPTA=(អនុក្រឹត្យលេខ ១៤៩), យោងតាមគេហទំព័ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ច្បាប់ស្តីតំបន់សេដ្ឋកិច្ចពិសេសត្រូវបានព្រាងឡើងនៅឆ្នាំ២០០៨ ទោះជាយ៉ាងណាសេចក្តីព្រាងច្បាប់នេះស្ថិតនៅក្នុងការពិចារណារបស់រាជរដ្ឋាភិបាលកម្ពុជានៅឡើយទេតាមរយៈ កថាខណ្ឌ ទី១. http://www.cambodiainvestment.gov.kh/investment-scheme/the-special-economic-zones.html

[2] គ្រប់បទបញ្ញត្តិទាក់ទងនឹងតំបន់សេដ្ឋកិច្ចពិសេស ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បញ្ជីតំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជា ឆ្នាំ២០១៣ ទំព័រ១-២ http://www.customs.gov.kh/wp-content/uploads/2017/04/All-Regulations-related-to-SEZ-Eng.pdf ។ ព័ត៌មានមកទល់បច្ចុប្បន្នទាក់ទងនឹងចំនួនតំបន់សេដ្ឋកិច្ចពិសេសដែលមាននៅកម្ពុជាមិនទាន់មានផ្សាយជាជាសាធារណៈនូវឡើយទេ។

[3] «សាវតានៃតំបន់សេដ្ឋកិច្ចពិសេស» អង្គការទិន្នន័យអំពីការអភិវឌ្ឍនៅកម្ពុជា គិតត្រឹមថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ https://opendevelopmentcambodia.net/km/profiles/special-economic-zones/

សលាកប័ត្រព័ត៌មាននេះផ្តល់នូវទិដ្ឋភាពទូទៅនៃតំបន់សេដ្ឋកិច្ចពិសេសនៅប្រទេសកម្ពុជា និងបង្ហាញពីបញ្ហាដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។ នៅចុងបញ្ចប់នៃសលាកប័ត្រព័ត៌មាននេះក៏រួមមានបញ្ចូលអនុសាសន៍ស្តីពីច្បាប់ និងប្រតិបត្តិការរបស់តំបន់សេដ្ឋកិច្ចពិសេសនេះអោយស្របតាមកាតព្វកិច្ចរបស់ប្រទេសកម្ពុជា ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិផងដែរ។ សលាកប័ត្រព័ត៌មាននេះត្រូវបានផលិតដោយ ម.ស.ម.ក ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ពន្ធ ដែលធ្វើការដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនិងគោរពសិទ្ធិមនុស្សពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងព្រះរាជាណាចក្រកម្ពុជា («កម្ពុជា»)។

## អ្វីទៅជាតំបន់សេដ្ឋកិច្ចពិសេស?

ច្បាប់កម្ពុជាបានកំណត់តំបន់សេដ្ឋកិច្ចពិសេស ថាជាមជ្ឈមណ្ឌលពិសេសសម្រាប់អភិវឌ្ឍវិស័យសេដ្ឋកិច្ចដែលប្រមូលផ្តុំនូវសកម្មភាពឧស្សាហកម្ម និងសកម្មភាពពាក់ព័ន្ធដទៃទៀត ហើយអាចរាប់បញ្ចូលតំបន់ឧស្សាហកម្មទូទៅ ឬ តំបន់ផលិតកែច្នៃសម្រាប់នាំចេញ។ តំបន់សេដ្ឋកិច្ចពិសេសនីមួយៗ មានមណ្ឌលផលិតកម្ម និងអាចមានមណ្ឌលពាណិជ្ជកម្មសេរី មណ្ឌលសេវាកម្ម មណ្ឌលលំនៅដ្ឋាន និងមណ្ឌលទេសចរណ៍។[4]

តំបន់សេដ្ឋកិច្ចពិសេស គឺជាតំបន់ភូមិសាស្ត្រដែលមានបទបញ្ញត្តិរដ្ឋបាលពិសេសជាក់លាក់ដែលត្រូវអនុវត្តតាមដូចជា ភាពផ្សេងៗគ្នានៃរបបពន្ធដា ឬជាការទទួលបានអត្ថប្រយោជន៍ពីការរៀបចំតាមផ្លូវច្បាប់ ឬភស្តុភារផ្សេងៗគ្នាដើម្បីទាក់ទាញពាណិជ្ជកម្ម និងការវិនិយោគ (ជាពិសេសមកពីបរទេស)។[5] ឧទាហរណ៍ អាចមានទម្រង់ផ្សេងៗគ្នាដូចជា តំបន់ផលិតកែច្នៃនាំចេញ ឬកំពង់ផែសេរី ស្ថិតនៅក្នុងទីតាំង ដែលស្ថានភាពក្នុងទីតាំងនោះមានដូចជាហេដ្ឋារចនាសម្ព័ន្ធមិនទាន់ល្អ ដែលអាចបង្អាក់ដល់ការវិនិយោគផងដែរ។[6] តំបន់ដែលមានការអនុញ្ញាតទទួលបានការអនុគ្រោះដោយមានបទប្បញ្ញត្តិជាអាទិភាពដូចជាការលើកលែងពន្ធលើប្រាក់ចំណេញ និងពន្ធនាំចូលក៏ដូចជាមជ្ឈមណ្ឌលការិយាល័យច្រកចេញចូលតែមួយ ដែលមានតំណាងមកពីនាយកដ្ឋានផ្សេងៗគ្នារបស់រដ្ឋាភិបាលដើម្បីបំពេញតម្រូវការផ្នែករដ្ឋបាលទាំងអស់សម្រាប់សកម្មភាពដោយផ្ទាល់នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។[7]

តំបន់សេដ្ឋកិច្ចពិសេសត្រូវបានរីករាលដាលនៅទូទាំងពិភពលោកនិងជាពិសេសនៅអាស៊ីបូព៌ាដែលមានសក្តានុពលភាព «ជោគជ័យយ៉ាងខ្លាំង»។[8] តំបន់នេះបានទាក់ទាញការវិនិយោគបរទេសដែលជួយសម្រួលដល់ការ

---

[4] អនុក្រឹត្យលេខ ១៤៨ (មាត្រា ២) https://opendevelopmentcambodia.net/km/dataset/?id=sub-decree-on-organization-and-management-of-special-economic-zone&search_query=P3M9c3BlY2lhbCtlY29ub21pYyt6b25lJnR5cGU9bGF3c19yZWNvcmQmcGFnZT0w

[5] ធនាគារអភិវឌ្ឍន៍អាស៊ី "តំបន់សេដ្ឋកិច្ចពិសេស" ចេញខែតុលា ឆ្នាំ២០១៥ ទំព័រទី១ កថាខណ្ឌទី២ https://www.adb.org/sites/default/files/publication/175236/ewp-459.pdf

[6] ដូចប្រភពខាងលើ

[7] អនុក្រឹត្យ លេខ ១៤៨ មាត្រា ៦ (៦.១) និង មាត្រា៤ (៤.៣) https://opendevelopmentcambodia.net/km/dataset/?id=sub-decree-on-organization-and-management-of-special-economic-zone&search_query=P3M9c3BlY2lhbCtlY29ub21pYyt6b25lJnR5cGU9bGF3c19yZWNvcmQmcGFnZT0w

[8] គោលនយោបាយសង្គម និងតំបន់សេដ្ឋកិច្ចពិសេសក្នុងអនុតំបន់មេគង្គ កាសែតអន្តរជាតិស្តីពីគុណភាពសង្គម ភាគ៣ លេខ១ ឆ្នាំ២០១៣ ទំព័រ ៤៩ https://www.jstor.org/stable/23971881?seq=1#page_scan_tab_contents

ធ្វើពាណិជ្ជកម្មសេរី បង្កើតការងារ និងកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងចំណោមអត្ថប្រយោជន៍សេដ្ឋកិច្ចផ្សេងៗទៀត។[9] ជាងនេះទៅទៀត ភាគច្រើននៃអ្នកធ្វើការងារនៅតំបន់សេដ្ឋកិច្ចពិសេសគឺជាស្ត្រី ដែលជាការចូលរួមជួយផ្តល់អំណាចខាងសេដ្ឋកិច្ចរបស់ស្ត្រី។[10] យោងទៅតាមធនាគារពិភពលោកបង្ហាញថា តំបន់សេដ្ឋកិច្ចពិសេសបានផ្តល់ការងារ បង្កើនការចូលរួមផ្នែកសេដ្ឋកិច្ចពីសំណាក់ស្ត្រី និងមានផលជះយ៉ាងសំខាន់ទៅលើការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។[11] ទោះជាយ៉ាងណាក៏ដោយ តាមការគូសបញ្ជាក់បន្ថែមនៅខាងក្រោមនេះ ការបង្កើតនិងប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេសមួយចំនួនបានជះឥទ្ធិពលអវិជ្ជមានដល់សិទ្ធិមនុស្សរបស់សហគមន៍ ដែលតំបន់សេដ្ឋកិច្ចពិសេសត្រូវបានបង្កើតឡើងនៅលើដីរបស់ពួកគេ និងប៉ះពាល់ដល់សិទ្ធិរបស់កម្មករដែលធ្វើការនៅតំបន់សេដ្ឋកិច្ចពិសេសនោះ។

## តើអ្នកណាទទួលខុសត្រូវលើតំបន់សេដ្ឋកិច្ចពិសេស?

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា («ក.អ.ក») ដែលមានមានសមាសភាពចូលរួមពីទេសរដ្ឋមន្ត្រីមកពីបណ្តាស្ថាប័នរបស់រដ្ឋាភិបាលដែលពាក់ព័ន្ធ ហើយមាននាយករដ្ឋមន្ត្រីជាប្រធាន[12]មានភារកិច្ចក្នុងការស្តារការអភិវឌ្ឍ និងត្រួតពិនិត្យសកម្មភាពវិនិយោគ ហើយជាទូទៅទទួលខុសត្រូវចំពោះការបង្កើត និងប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេស។[13] គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា («គ.ស.ព») ដែលជាអង្គភាពមួយក្នុងចំណោមអង្គភាព

---

[9] តំបន់សេដ្ឋកិច្ចពិសេស និងការទាញយកតម្លៃពីតំបន់មេគង្គដែលចេញដោយអង្គការ Focus on The Global South ខែកក្កដា ឆ្នាំ២០១៧ ទំព័រទី១១ កថាខណ្ឌទី២, អាចអានបាននៅលើគេហទំព័រ អង្គទន្និន័យអំពីការអភិវឌ្ឍចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៧ កថាខណ្ឌទី ១, https://opendevelopmentcambodia.net/km/topics/special-economic-zones/

[10] មានការប៉ាន់ប្រមាណថាយ៉ាងហោចណាស់ ៩៥% នៃកម្មករដែលធ្វើការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជាគឺជាស្ត្រី។ «តំបន់សេដ្ឋកិច្ចពិសេសកម្ពុជា» ធនាគារអភិវឌ្ឍន៍អាស៊ី, តុលា ២០១៥, ទំព័រ ៨. កថាខណ្ឌ ៣. https://www.adb.org/sites/default/files/publication/175236/ewp-459.pdf

[11] ការលើកកម្ពស់សេដ្ឋកិច្ចតាមរយៈពង្រឹងសិទ្ធិអំណាចស្ត្រី តំបន់សេដ្ឋកិច្ចពិសេស ធនាគារពិភពលោកឆ្នាំ ២០១១ ប្រតិបត្តិសង្ខេប។ ទំព័រ X កថាខណ្ឌ ៣-៥ សូមមើលផងដែរ, http://documents.worldbank.org/curated/en/657561468148771219/pdf/727040WP0Box370sez0and0women0global.pdf
ទោះជាយ៉ាងណាក៏ដោយរបាយការណ៍ក៏បង្ហាញផងដែរថាស្ត្រីត្រូវរងផលប៉ះពាល់ដោយជម្លោះដីធ្លីដែលពាក់ព័ន្ធនឹងតំបន់សេដ្ឋកិច្ចពិសេសនិងបញ្ហាសិទ្ធិមនុស្សដែលពាក់ព័ន្ធនឹងតំបន់សេដ្ឋកិច្ចពិសេស។ សូមមើលរបាយការណ៍ចំណងជើង ស្ត្រីក្នុងជម្លោះដីធ្លីនៅកម្ពុជារបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាខែកញ្ញា ឆ្នាំ ២០១៦ https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=116&id=5&lang=khm សៀវភៅណែនាំស្តីពីសហជីពពាណិជ្ជកម្មលើតំបន់កែច្នៃ របស់អង្គការអន្តរជាតិខាងការងារ ឆ្នាំ ២០១៤ ទំព័រ ១៣-១៤ http://119.15.85.2:81/2Q2W3B7F960BCEBD2EF7A0FFC123DFE535E01BAA1280_unknown_63D4468F0C6C7E8D07D8EE1FBD1B4FCE7D443345_3/www.ilo.org/wcmsp5/groups/public/---ed_dialogue/---actrav/documents/publication/wcms_324632.pdf

[12] ច្បាប់ស្តីពីវិនិយោគនៅកម្ពុជា ឆ្នាំ ១៩៩៤ មាត្រា១ http://sithi.org/admin/upload/law/section10_003_1994.pdf
តំបន់សេដ្ឋកិច្ចពិសេស និងការទាញយកតម្លៃពីតំបន់មេគង្គដែលចេញដោយអង្គការ Focus on The Global South ឆ្នាំ ២០១៧ ទំព័រ ១៦ កថាខណ្ឌទី ២. https://focusweb.org/system/files/khmer_sezmekongcasestudy_web_0.pdf

[13] អនុក្រឹត្យលេខ ១៤៩ មាត្រា ១០ (១) ១០ (៩) ១៣, ៣០ https://opendevelopmentcambodia.net/km/dataset/?id=sub-decree-no149-on-the-organization-and-functioning-of-the-council-for-development-of-cambodia&search_query=P3M9Q291bmNpbCtmb3IrRGV2ZWxvcG1lbnQrb2YrQ2FtYm9kaWEmdHlwZT1sYXdzX3JlY29yZCZwYWdlPTA

ទាំងបួនដែលជាសមាជិករបស់ ក.អ.ក[14]ទទួលបន្ទុកអភិវឌ្ឍន៍និងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជា។[15] គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាជាអ្នកគ្រប់គ្រងប្រតិបត្តិការរបស់តំបន់សេដ្ឋកិច្ចពិសេស[16]និងត្រូវដាក់របាយការណ៍សង្ខេប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិរបស់ ក.អ.ក។[17] គ.ស.ព ត្រូវបានបង្កើតឡើងដោយតំណាងមកពីស្ថាប័នរដ្ឋាភិបាល[18] ហើយមានបែកចែកជា ៤ នាយកដ្ឋានដូចជា ផ្នែកគោលនយោបាយនិងផែនការ ផ្នែកប្រតិបត្តិការ និងគ្រប់គ្រង ផ្នែកវិភាគគម្រោង និងចុះបញ្ជី និងផ្នែករដ្ឋបាល។[19]

ក្នុងនាមជាស្ថាប័នសាធារណៈធ្វើសកម្មភាពជំនួសរាជរដ្ឋាភិបាលកម្ពុជា ក.អ.ក និង គ.ស.ព ត្រូវតែគោរពសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ដូចដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងសន្ធិសញ្ញាអន្តរជាតិដែលកម្ពុជាបានផ្តល់សច្ចាប័ន។[20] ទោះបីជាយ៉ាងណាពុំមានយន្តការប្តឹងតវ៉ា ឬផ្តល់ព័ត៌មានប្រកបដោយប្រសិទ្ធភាពណាមួយដែលអនុញ្ញាតឱ្យសហគមន៍រងផលប៉ះពាល់ពីតំបន់សេដ្ឋកិច្ចពិសេស អាចរាយ

---

14 រួមគ្នាជាមួយក្រុមប្រឹក្សាស្តារឡើងវិញ និងអភិវឌ្ឍន៍កម្ពុជាក្រុមប្រឹក្សាវិនិយោគកម្ពុជានិងអគ្គលេខាធិការ CDC សូមមើលអនុក្រឹត្យលេខ 147 មាត្រា 2, https://opendevelopmentcambodia.net/km/dataset/?id=sub-decree-no-147-on-the-organization-and-functioning-of-the-council-for-development-of-cambodia&search_query=P3M9Q291bmNpbCtmb3IrRGV2ZWxvcG1lbnQrb2YrQ2FtYm9kaWEmdHlwZT1sYXdzX3JlY29yZCZwYWdlPTA=

15 អនុក្រឹត្យលេខ ១៤៨ មាត្រា ២ https://opendevelopmentcambodia.net/km/dataset/?id=sub-decree-on-organization-and-management-of-special-economic-zone&search_query=P3M9c3BlY2lhbCtlY29ub21pYyt6b25lJnR5cGU9bGF3c19yZWNvcmQmcGFnZT0w អនុក្រឹត្យលេខ ១៤៩ មាត្រា ២៩ https://opendevelopmentcambodia.net/km/dataset/?id=sub-decree-no149-on-the-organization-and-functioning-of-the-council-for-development-ofcambodia&searchquery=P3M9Q291bmNpbCtmb3IrRGV2ZWxvcG1lbnQrb2YrQ2FtYm9kaWEmdHlwZT1sYXdzX3JlY29yZCZwYWdlPTA=

16 អនុក្រឹត្យលេខ ១៤៩ មាត្រា ២៩ https://opendevelopmentcambodia.net/km/dataset/?id=sub-decree-no149-on-the-organization-and-functioning-of-the-council-for-development-of-cambodia&search_query=P3M9Q291bmNpbCtmb3IrRGV2ZWxvcG1lbnQrb2YrQ2FtYm9kaWEmdHlwZT1sYXdzX3JlY29yZCZwYWdlPTA= តំបន់សេដ្ឋកិច្ចពិសេស ផ្នែក ៤ ការគ្រប់គ្រងសំណងនៅតំបន់សេដ្ឋកិច្ចពិសេស ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា http://www.cambodiainvestment.gov.kh/investment-scheme/the-special-economic-zones.html

17 អនុក្រឹត្យលេខ ១៤៩ មាត្រា ២៩ (៤) https://opendevelopmentcambodia.net/km/dataset/?id=sub-decree-no149-on-the-organization-and-functioning-of-the-council-for-development-of-cambodia&search_query=P3M9Q291bmNpbCtmb3IrRGV2ZWxvcG1lbnQrb2YrQ2FtYm9kaWEmdHlwZT1sYXdzX3JlY29yZCZwYWdlPTA=

18 អនុក្រឹត្យលេខ ១៤៩ មាត្រា ៣៣ (៣) (ក) https://opendevelopmentcambodia.net/km/dataset/?id=sub-decree-no149-on-the-organization-and-functioning-of-the-council-for-development-of-cambodia&search_query=P3M9Q291bmNpbCtmb3IrRGV2ZWxvcG1lbnQrb2YrQ2FtYm9kaWEmdHlwZT1sYXdzX3JlY29yZCZwYWdlPTA= ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីស្តីការគណរដ្ឋមន្ត្រី ក្រសួង ផែនការ ក្រសួង ពាណិជ្ជកម្ម ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង និងស្ថាប័នពាក់ព័ន្ធដទៃទៀត

19 អនុក្រឹត្យលេខ ១៤៩ មាត្រា ៦ https://opendevelopmentcambodia.net/km/dataset/?id=sub-decree-no149-on-the-organization-and-functioning-of-the-council-for-development-of-cambodia&search_query=P3M9Q291bmNpbCtmb3IrRGV2ZWxvcG1lbnQrb2YrQ2FtYm9kaWEmdHlwZT1sYXdzX3JlY29yZCZwYWdlPTA=

20 រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣១ http://sithi.org/admin/upload/law/section_01_01_KHM.pdf ការអនុវត្តដោយផ្ទាល់នូវបទប្បញ្ញត្តិច្បាប់អន្តរជាតិទាំងនេះត្រូវបានទទួលស្គាល់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ «ក្រុមប្រឹក្សាធម្មនុញ្ញ» ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨ សេចក្តីសម្រេចលេខ. ០៩២/០០៣/២០០៧ សូមមើលផងដែរអនុក្រឹត្យលេខ ១៤៨ អនក្រឹត្យ លេខ១១ ដែលចែងថាសិទ្ធិនិងការការពារដែលមាននៅក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាអនុវត្តនៅក្នុងតំបន់ហើយបញ្ជាក់យ៉ាងច្បាស់ថាកម្មករមានសិទ្ធិទទួលបានការការពារផ្សេងៗដូចដែលបានបញ្ជាក់នៅក្នុងច្បាប់ការងារឆ្នាំ ១៩៩៧ និងលក្ខន្តិកៈពាក់ព័ន្ធផ្សេងទៀត។ មាត្រា ១៥ នៃច្បាប់ស្តីពីការវិនិយោគឆ្នាំ ១៩៩៧ ចែងថាច្បាប់និងបទបញ្ញត្តិពាក់ព័ន្ធទាំងអស់ត្រូវបានអនុវត្តលើគ្រប់សកម្មភាពនៅសេដ្ឋកិច្ចពិសេស ប្រសិនបើមិនបានបញ្ជាក់នៅក្នុងអនុក្រឹត្យនោះទេ http://ibccambodia.com/wp-content/uploads/2016/06/Law_on_investment_English.pdf.

ការណ៍អំពីការរំលោភបំពានសិទ្ធិមនុស្សដែលផ្ទុយនឹងកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាថារាល់ការរំលោភសិទ្ធិមនុស្សត្រូវបានធ្វើការស៊ើបអង្កេតឱ្យបានត្រឹមត្រូវនិងដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាពឡើយ។[21]

## តើមានលក្ខខណ្ឌចាំបាច់អ្វីខ្លះដើម្បីទទួលបានតំបន់សេដ្ឋកិច្ចពិសេស?

ដើម្បីទទួលបានការអនុញ្ញាត តំបន់សេដ្ឋកិច្ចពិសេស ត្រូវធ្វើតាមលក្ខខណ្ឌដូចខាងក្រោម[22]៖

- ទីតាំងត្រូវមានទំហំយ៉ាងហោចណាស់ ៥០ ហិកតាឡើងទៅ ហើយព័ទ្ធជុំវិញទៅដោយរបង។
- ត្រូវមានមណ្ឌលផលិតកម្ម និងអាចមានមណ្ឌលតំបន់ពាណិជ្ជកម្មសេរី មណ្ឌលសេវាកម្ម មណ្ឌលលំនៅដ្ឋាន និងមណ្ឌលទេសចរណ៍។
- តំបន់នេះតម្រូវអោយមានហេដ្ឋារចនាសម្ពន្ធ ផ្លូវថ្នល់ អគារការិយាល័យ ទឹក ប្រព័ន្ធអគ្គីសនី និងប្រពន្ធលូ វិធានការការពារបរិស្ថាន។
- តំបន់សេដ្ឋកិច្ចពិសេសត្រូវគោរពតាមការណែនាំរបស់ក្រសួង ឬស្ថាប័នពាក់ព័ន្ធ។

នៅពេលដែលតំបន់សេដ្ឋកិច្ចពិសេសត្រូវបានទទួលការអនុញ្ញាតិឲ្យប្រតិបត្តិការនោះ អនុក្រឹត្យនឹងត្រូវបានអនុម័តដើម្បីកំណត់ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស និងព្រំប្រទល់ខ័ណ្ឌសីមានៃតំបន់នោះ។[23]

## បញ្ហាសិទ្ធិមនុស្សដែលពាក់ព័ន្ធនៅនឹងតំបន់សេដ្ឋកិច្ចពិសេស

**១. កង្វះតម្លាភាព និងការផ្សព្វផ្សាយជាសាធារណៈ ៖** មានការខ្វះខាតព័ត៌មានដែលអាចរកបានជាសាធារណៈទាក់ទងនឹងតំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជា រួមទាំងខ្វះខាតការផ្សព្វផ្សាយជាសាធារណៈអំពីអនុក្រឹត្យដែលបង្កើតតំបន់សេដ្ឋកិច្ចពិសេសផងដែរ។

- សហគមន៍ដែលរងផលប៉ះពាល់ និងអ្នកដែលគាំទ្រពួកគាត់ត្រូវបានគេរាំងខ្ទប់ការទទួលបានព័ត៌មានសំខាន់ៗ និងមិនអាចការពារសិទ្ធិរបស់ពួកគេបានត្រឹមត្រូវឡើយ។
- ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានដែលនឹងអនុម័តនាពេលខាងមុខនេះ ប្រហែលជានឹងអាចដោះស្រាយបញ្ហាទាំងនេះបានពេញលេញ ឬក៏បានមួយផ្នែកណាមួយនៃកង្វល់ទាំងនេះ។[24] ថ្វីបើនៅមានបញ្ហាមួយ

---

[21] កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ២ (៣), http://cambodia.ohchr.org/sites/default/files/Treaty/ICCPR_2009K.pdf សូមមើលផងដែរ «មតិយោបល់ទូទៅលេខ ៣១ លក្ខណៈនៃកាតព្វកិច្ចទូទៅនៃរដ្ឋជាភាគីនៃកតិកាសញ្ញា» គណៈកម្មាធិការសិទ្ធិមនុស្ស អ ស ប ២០០៤ កថាខណ្ឌ ៨, ៩, ១៥, ១៦, https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CCPR%2fC%2f21%2fRev.1%2fAdd.13&Lang=en.

[22] អនុក្រឹត្យលេខ ១៤៨ មាត្រា ២ និង ៣.១ https://opendevelopmentcambodia.net/km/dataset/?id=sub-decree-on-organization-and-management-of-special-economic-zone&search_query=P3M9c3BlY2lhbCtlY29ub21pYyt6b25lJnR5cGU9bGF3c19yZWNvcmQmcGFnZT0w

[23] អនុក្រឹត្យលេខ ១៤៨ មាត្រា ៣(៣.២ (ចំណុច៥)) ៣.១ https://opendevelopmentcambodia.net/km/dataset/?id=sub-decree-on-organization-and-management-of-special-economic-zone&search_query=P3M9c3BlY2lhbCtlY29ub21pYyt6b25lJnR5cGU9bGF3c19yZWNvcmQmcGFnZT0w

[24] សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានជាសាធារណៈសម្រាប់ការអនុវត្ត «សិទ្ធិដឹងឮជាសាធារណៈ» ត្រូវបានរៀបចំឡើង។ នៅក្នុងសេចក្តីព្រាងនេះ មាត្រា 6 ចែងថាវាគឺជាកាតព្វកិច្ចរបស់រដ្ឋក្នុងការធ្វើបច្ចុប្បន្នភាពនិងផ្សព្វផ្សាយព័ត៌មានទាក់ទងនឹង «ច្បាប់ បទបញ្ញា គោលនយោបាយ សេចក្តីសម្រេចនិងកាតព្វកិច្ចរបស់ស្ថាប័នសាធារណៈទាក់ទងនឹងសិទ្ធិសេរីភាពកាតព្វកិច្ចនិងផលប្រយោជន៍សាធារណៈ» ។ សូមមើលពង្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានក្រសួងព័ត៌មាន http://www.a2i.info.gov.kh/html/law.php

ចំនួនមិនទាន់ជាច់ស្រេចនៅក្នុងសេចក្តីព្រាងច្បាប់នេះក៏ដោយ[25] ប៉ុន្តែច្បាប់នេះអាចប្រើសម្រាប់ស្នើសុំពត៌មានអំពីតំបន់សេដ្ឋកិច្ចពិសេស។

**២. ការបណ្តេញចេញដោយបង្ខំ ៖** សហគមន៍រស់កន្លែង ដែលតំបន់សេដ្ឋកិច្ចពិសេសនឹងត្រូវបង្កើតឡើងនៅទីនោះនាពេលអនាគតអាចនឹងត្រូវបានបណ្តេញចេញដោយបង្ខំក្នុងពេលណាមួយ ហើយនេះគឺជាផ្នែកមួយនៃដំណើរការខ្វះតម្លាភាព និងយុត្តិធម៌ដោយគ្មានការពិគ្រោះយោបល់ជាមុន និងដោយគ្មានសំណងត្រឹមត្រូវ និងយុត្តិធម៌ឡើយ។

- ច្បាប់អន្តរជាតិតម្រូវឱ្យមានការពិគ្រោះយោបល់ត្រឹមត្រូវជាមួយសហគមន៍ ដែលរងផលប៉ះពាល់មុនពេលគម្រោងអភិវឌ្ឍន៍ណាមួយចាប់ផ្តើម។[26] អ្វីដែលសំខាន់ជាងនេះគឺ នៅពេលដែលអ្នកទទួលរងផលប៉ះពាល់ជាសហគមន៍ជនជាតិដើមភាគតិច។[27]
- មនុស្សគ្រប់រូបមានសិទ្ធិលើអចលនទ្រព្យ[28] និងលំនៅដ្ឋានសមរម្យ[29] និងគ្មានជនណាម្នាក់ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋានបានឡើយ។[30]
- នៅពេលសិទ្ធិមនុស្សត្រូវបានរំលោភ រដ្ឋត្រូវតែធានាថាមនុស្សត្រូវតែមានសិទ្ធិទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធិភាព។[31]

**៣. ប្រាក់ឈ្នួលទាប និងលក្ខខណ្ឌការងារ ៖** ការប្រើប្រាស់កម្លាំងពលកម្មដែលមានប្រាក់ឈ្នួលទាប និងកង្វះបទបញ្ញត្តិទាក់ទងនឹងប្រាក់ឈ្នួលមុនពេលដែលច្បាប់ស្តីពីប្រាក់ឈ្នួលអប្បរមាត្រូវបានអនុម័តក្នុង ខែកក្កដា ឆ្នាំ២០១៨ បណ្តាលឱ្យមានឱកាសកេងប្រវ័ញ្ចកម្លាំងពលកម្មរបស់កម្មករធ្វើការលើសម៉ោង និង ទទួលបានប្រាក់ឈ្នួលតិចតួច។[32]

---

[25] ទោះយ៉ាងណាក៏ដោយគ្រឹះស្ថានសាធារណៈអាចនៅតែមានអំណាចដែលអាចសម្រេចចិត្តកាត់បន្ថយឬពន្យាពេលវេលានៃការរក្សាព័ត៌មានសម្ងាត់ទាំងផ្នែកឬទាំងស្រុងដោយផ្អែកលើដែនកំណត់ជាក់លាក់។ ដែនកំណត់ទាំងនេះគួរតែត្រូវបានបង្កើតឡើងនិងត្រូវបានបង្កើតយ៉ាងច្បាស់ហើយគួរអនុវត្តតាមតម្រូវការរបស់យុត្តិសាស្ត្រអន្តរជាតិ។ សូមមើលសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានក្រសួងព័ត៌មាន http://www.a2i.info.gov.kh/html/law.php សូមមើលផងដែរ ឆ្នាំ ២០១១ ការវិភាគលើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន" អង្គការ មាត្រា ១៩ ទំព័រទី ១១-១៤, https://www.article19.org/data/files/medialibrary/2739/11-09-20-Cambodia.pdf

[26] យោបល់ទូទៅទី៧ សិទ្ធិទទួលបានលំនៅដ្ឋានសមរម្យ (មាត្រា ១១ (១) នៃ កតិកាសញ្ញា) ការបណ្តេញចេញដោយបង្ខំ. គណកម្មាធិការសិទ្ធិសេដ្ឋកិច្ចសង្គម និង វប្បធម៌ ឆ្នាំ១៩៩៧ កថាខណ្ឌ ១៥ https://www.ohchr.org/Documents/Issues/Housing/Handbook_Khmer.pdf

[27] សលាកប័ត្រព័ត៌មាន «សិទ្ធិយល់ព្រមដោយពេញចិត្ត ដោយបានប្រាប់ឲ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ» របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ខែសីហា ឆ្នាំ២០១៧ ទំព័រ ១ដល់៣ https://cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=77&id=5&lang=khm

[28] កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារបន្ថែម មាត្រា ១៧ http://119.15.85.3/2Q2W62F7D65B02505A6681CEF5BD149348245A9719B3_unknown_A362F3547AFFCD72080090F3EE9167B948FC6C20_1/cambodia.ohchr.org/sites/default/files/Treaty/ICCPR_2009K.pdf

[29] កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មាត្រា ១១ (១) https://www.slideshare.net/khmerbook/ss-62804473

[30] កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារបន្ថែម http://119.15.85.3/2Q2W62F7D65B02505A6681CEF5BD149348245A9719B3_unknown_A362F3547AFFCD72080090F3EE9167B948FC6C20_1/cambodia.ohchr.org/sites/default/files/Treaty/ICCPR_2009K.pdf

[31] កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារបន្ថែម មាត្រា ២(៣) (ក) នឹង (២៦) http://119.15.85.3/2Q2W62F7D65B02505A6681CEF5BD149348245A9719B3_unknown_A362F3547AFFCD72080090F3EE9167B948FC6C20_1/cambodia.ohchr.org/sites/default/files/Treaty/ICCPR_2009K.pdf

[32] «តំបន់សេដ្ឋកិច្ចពិសេសកម្ពុជា» ធនាគារអភិវឌ្ឍន៍អាស៊ីខែតុលាឆ្នាំ២០១៥, ទំព័រ ៨ https://www.adb.org/sites/default/files/publication/175236/ewp-459.pdf «ការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងលក្ខខណ្ឌការងារនៅក្នុងតំបន់កែច្នៃនាំចេញ៖ ការស្ទង់មតិស្តីពីនិន្នាការ»អង្គការអន្តរជាតិខាងការងារ ឆ្នាំ២០០៨ ទំព័រ ២៥, ៣៤, http://citeseerx.ist.psu.edu/viewdoc/download?doi=10.1.1.490.1514&rep=rep1&type=pdf នៅខាងក្នុងក្រុមហ៊ុនសាជីវកម្មយូធ្យូពីដែលច្បាប់របស់រដ្ឋ

- ប្រាក់ឈ្នួលសមរម្យគឺជាសិទ្ធិមនុស្ស ៖ អ្នកដែលធ្វើការងារមានសិទ្ធិទទួលបានលាភការដោយសមធម៌ និងពេញចិត្ត។[33]
- ប្រាក់ឈ្នួលទាបគឺជាកត្តារាំងស្ទះដល់ការទទួលបានសិទ្ធិមនុស្សបន្ថែមជាច្រើនទៀត ដូចជាសិទ្ធិទទួលបានជីវភាពសមរម្យ រួមមានម្ហូបអាហារ សម្លៀកបំពាក់ និងលំនៅដ្ឋាន។[34]

**៤. ការរឹតបន្តឹងធ្ងន់ធ្ងរលើសេរីភាពបញ្ចេញមតិ ជួបប្រជុំ និងសមាគមៈ** ទោះបីជាសហជីពមិនត្រូវបានផាត់ចេញពីតំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជាក៏ដោយ ក៏សមាជិកនៃសហជីពនិងសមាគមដទៃទៀតត្រូវបានរារាំង និងមានការរំលោភបំពានសេរីភាពនៃការបង្កើតសមាគមយ៉ាងច្រើន[35] លើសពីនេះសមាជិកសហជីពបានរាយការណ៍ថាបានប្រឈមនឹងការរើសអើងយ៉ាងខ្លាំង ការបំភិតបំភ័យ និងជួនកាលមានទាំងអំពើហិង្សា ក៏ដូចជាការរំខានយាយីពីប្រព័ន្ធតុលាការផងដែរ។[36]

- ច្បាប់របស់កម្ពុជារួមទាំងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ ត្រូវតែបានគោរពនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។ មាត្រា ១១ នៃអនុក្រឹត្យលេខ ១៤៨ បញ្ជាក់ម្តងទៀតថា កម្មករនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសមានសិទ្ធិទទួលបានការការពារនានាដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ការងារ និងលក្ខន្តិកៈផ្សេងៗ

---

ធម្មនុញ្ញនិងច្បាប់ការងារមិនត្រូវបានដាក់បញ្ចាំនោះទេនៅពេលនេះ,២៥ កក្កដា ២០១៦, http://inthesetimes.com/features/special-economic-zones-corporate-utopia-capitalism.htmlសៀវភៅណែនាំស្តីពីសហជីពការងារលើតំបន់កែច្នៃនាំចេញអង្គការពលកម្មអន្តរជាតិឆ្នាំ២០១៥ទំព័រ៥០, http://119.15.85.2:81/2Q2W3B7F960BCEBD2EF7A0FFC123DFE535E01BAA1280_unknown_63D4468F0C6C7E8D07D8EE1FBD1B4FCE7D443345_3/www.ilo.org/wcmsp5/groups/public/---ed_dialogue/---actrav/documents/publication/wcms_324632.pdf
កម្មកររាប់រយនាក់សន្លប់នៅតំបន់សេដ្ឋកិច្ចពិសេសកណ្តាលភ្នំពេញ កាសែតភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ https://www.phnompenhpost.com/national/hundreds-workers-faint-kandal-sez. ។ ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមាត្រូវបានគេបោះឆ្នោតនៅខែកក្កដា ឆ្នាំ២០១៨ សូមមើលគេហទំព័រក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ http://www.mlvt.gov.kh/index.php?option=com_k2&view=item&id=957:%E1%9E%85%E1%9F%92%E1%9E%94%E1%9E%B6%E1%9E%94%E1%9F%8B%E1%9E%9F%E1%9F%92%E1%9E%8A%E1%9E%B8%E1%9E%96%E1%9E%B8%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%B6%E1%9E%80%E1%9F%8B%E1%9E%88%E1%9F%92%E1%9E%93%E1%9E%BD%E1%9E%9B%E1%9E%A2%E1%9E%94%E1%9F%92%E1%9E%94%E1%9E%94%E1%9E%9A%E1%9E%98%E1%9E%B6&Itemid=207&lang=en

[33] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) មាត្រា ២៣ (៣) http://cambodia.ohchr.org/sites/default/files/Softlaw/UNHR-KH.pdf , កតិកាសញ្ញអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មាត្រា ៧ (ក) (១) https://www.slideshare.net/khmerbook/ss-62804473

[34] កតិកាសញ្ញអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មាត្រា ១១ (១) https://www.slideshare.net/khmerbook/ss-62804473

[35] តំបន់សេដ្ឋកិច្ចពិសេស និងការទាញយកតម្លៃពីតំបន់មេគង្គដែលចេញដោយអង្គការ Focus on Global South , កក្កដា ២០១៧, ទំព័រ ២២, ២៤-២៥, https://focusweb.org/system/files/khmer_sezmekongcasestudy_web_0.pdf សូមមើលផងដែរនៅខាងក្នុងក្រុមហ៊ុន Utopia ដែលច្បាប់របស់រដ្ឋធម្មនុញ្ញនិងច្បាប់ការងារមិនត្រូវបានស្នើសុំនោះទេនាពេលថ្មីៗនេះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៦ ផ្នែកដែលមានចំណងជើងថា «Union Free ដោយ Design» http://inthesetimes.com/features/special-economic-zones-corporate-utopia-capitalism.html

[36] ទាំងនេះរួមបញ្ចូលការបណ្តេញចេញដោយអយុត្តិធម៌, ត្រូវបានចុះបញ្ជីនៅក្នុងបញ្ជីខ្មៅនិងត្រូវបានរារាំងពីការស្វែងរកការងារនៅក្នុងរោងចក្រផ្សេងទៀត, មើល 'តំបន់សេដ្ឋកិច្ចពិសេស និងការទាញយកតម្លៃពីតំបន់មេគង្គដែលចេញដោយអង្គការ,Focus on Global South, កក្កដា ២០១៧, ទំព័រ ២២-២៥ https://focusweb.org/system/files/sezs_and_value_extraction_in_the_mekong_english.pdf ឧទាហរណ៍កម្មករដែលធ្វើកូដកម្មនៅខេត្តកណ្តាលត្រូវបានគេរាយការណ៍ថាត្រូវបានផ្ទាំសន្តិសុខនៅថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ២០១៦។ ឧទាហរណ៍ វាយប្រហារខណៈពេលធ្វើការតវ៉ាប្រឆាំងនឹងការបណ្តេញបុគ្គលិកថ្មីៗចំនួន 8 នាក់ដែលកំពុងព្យាយាមបង្កើតសហជីព។ https://www.phnompenhpost.com/national/labour-unrest-continues សមាជិកសហជីពនៅក្នុងរបាយការណ៍សេដ្ឋកិច្ចពិសេសត្រូវប្រឈមនឹងការយាយីខាងតុលាការដោយប្រឈមនឹងពាក្យបណ្តឹងរដ្ឋប្បវេណីនិងព្រហ្មទណ្ឌរបស់ម្ចាស់រោងចក្របើទោះបីជាខ្វះភស្តុតាងក្តី។ ឧទាហរណ៍ការចាប់ខ្លួនអ្នកដឹកនាំសហជីពពីរនាក់ពីបទញុះញង់បន្ទាប់ពីមានការតវ៉ាដោយអហិង្សានៅក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញនៅឆ្នាំ ២០១៦ បន្ទាប់ពីពាក្យបណ្តឹងមួយត្រូវបានដាក់ដោយក្រុមហ៊ុនតំបន់សេដ្ឋកិច្ចពិសេសមួយសូមមើលការស្ទង់មតិពីការរំលោភលើសិទ្ធិសហជីពកម្ពុជា។ សហព័ន្ធសហជីពអន្តរជាតិនៅថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១៦ ផ្នែកដែលមានចំណងជើងថា «មេដឹកនាំសហជីពពីររូបត្រូវបានកាត់ទោសពីបទរំលោភបំពានច្បាប់» https://survey.ituc-csi.org/Cambodia.html?lang=en#tabs-3 សូមមើលផងដែរ «រដ្ឋមន្ត្រីក្រសួងការងារគំរាមសហជីព», ខ្មែរតៃវ៉ាន់, ១ កញ្ញា ២០១៧, https://www.khmertimeskh.com/news/29212/labor-minister-threatens-unions/

ទៀត។ ជាពិសេសសិទ្ធិក្នុងការបង្កើតសហជីពត្រូវបានលើកឡើងក្នុងមាត្រា ៣៦ នៃរដ្ឋធម្មនុញ្ញ[37] មាត្រា ២៦៦ នៃច្បាប់ការងារ ឆ្នាំ១៩៩៧[38] និងមាត្រា ៥ នៃច្បាប់សហជីពដែលមានភាពចម្រូងចម្រាសឆ្នាំ ២០១៦។[39]

- រដ្ឋធម្មនុញ្ញកម្ពុជាក៏បានការពារសិទ្ធិធ្វើកូដកម្មនិងសិទ្ធិធ្វើបាតុកម្មដោយសន្តិវិធីផងដែរ។[40]

**ករណីសិក្សា៖** អ៊ឹម.ឌី.អេស តំបន់សេដ្ឋកិច្ចពិសេសថ្មដា ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់

ក្នុងឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឱ្យមានការបង្កើតតំបន់សេដ្ឋកិច្ចពិសេសថ្មដា អ៊ឹម.ឌី.អេស នៅឃុំថ្មដា ជិតព្រំប្រទល់ប្រទេសកម្ពុជា និងប្រទេសថៃ។ តំបន់សេដ្ឋកិច្ចពិសេសត្រូវបានបង្កើតឡើងដោយមាន៖ ទីផ្សារនាំចេញនាំចូល ដើម្បីផ្លាស់ប្តូរទំនិញ ឃ្លាំងសម្រាប់ផលិតផលកសិកម្ម កាស៊ីណូ ក្លឹបវាយកូនហ្គោល ក្លឹបកីឡា ចំណតរថយន្ត និងស្ថានីយ៍ប្រេងឥន្ទនៈ ដែលមានទំហំ ២.២៦៥ហិកតា។[41] ក្រុមហ៊ុនទ្រីភាពគ្រុប ខូអេលធីឌី ដែលគ្រប់គ្រងដោយឧកញ៉ាទ្រីភាពជាអ្នកគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។[42] សហគមន៍មូលដ្ឋានបានរាយការណ៍ថាមិនដែលឃើញអនុក្រឹត្យបង្កើតតំបន់សេដ្ឋកិច្ចពិសេស និងមិនត្រូវបានពិគ្រោះយោបល់ឱ្យបានត្រឹមត្រូវ មុនពេលបង្កើតតំបន់សេដ្ឋកិច្ចពិសេសនោះទេ។ លើសពីនេះទៀតប្រជាពលរដ្ឋជាច្រើនបានរាយការណ៍ថាត្រូវបានគេបង្ខំឱ្យចាកចេញពីដីរបស់ពួកគាត់ដោយគ្មានការជូនដំណឹងជាមុនថែមទាំងមានការប្រើហឹង្សា។ ពួកគាត់ខ្លះបានឃើញផ្ទះនិងទ្រព្យសម្បត្តិរបស់ខ្លួនត្រូវបានបំផ្លាញចោលហើយនៅពេលមានការតវ៉ា សមាជិកសហគមន៍ខ្លះត្រូវបានចាប់ដាក់ខ្នោះដៃ និងគម្រាមដោយការចាប់ខ្លួន។ ប្រជាពលរដ្ឋ ៩៧ គ្រួសារមកពី៣ ភូមិ [43] ផ្សេងគ្នា នៅក្នុងឃុំថ្មដាបានរងប៉ះពាល់ដោយជម្លោះដីធ្លី។ ជាលទ្ធផលនៃជម្លោះដីធ្លីនេះ សមាជិកសហគមន៍ដែលទទួលរងផលប៉ះពាល់បានបាត់បង់ដីចំការ និងជីវភាពរស់នៅ ដូច្នេះពួកគាត់ក៏មិនអាចបញ្ជូនកូនទៅសាលារៀនបានដែរ។ ក្រុមគ្រួសារទាំងនោះបាន

---

[37] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា http://119.15.85.3:81/2Q2W088BA2593740AE286CF790A9A7D9B5353B6BD2E0_unknown_948A2E119C41EDCC17F31142DB1D64870583C991_2/sithi.org/admin/upload/law/2008_02_19_Constitution(KH)_including%20Amendment%20(1).pdf

[38] ច្បាប់ការងារឆ្នាំ ១៩៩៧ http://www.nac.org.kh/tv/kh/ViewLawFile.aspx?LawDID=241

[39] ច្បាប់សហជីព ឆ្នាំ ២០១៦ http://119.15.85.3:81/2Q2W4D4B62CCBF37F15AC424801F88A371998D437768_unknown_928442EEDF0D2FE6C78CC1E5F6B2A582B1CAF47D_5/www.sithi.org/admin/upload/law/trade_union_law_kh.pdf សូមមើលផងដែរ សាលកប័ត្រព័ត៌មាន ស្តីពី ច្បាប់សហជីព មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ឆ្នាំ ២០១៦ https://cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=71&id=5&lang=khm

[40] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ៣៧ http://119.15.85.3:81/2Q2W088BA2593740AE286CF790A9A7D9B5353B6BD2E0 unknown_948A2E119C41EDCC17F31142DB1D64870583C991_2/sithi.org/admin/upload/law/2008_02_19_Constitution(KH)_including%20Amendment%20(1).pdf

[41] ទីស្តីការគណៈរដ្ឋមន្ត្រី, សេចក្តីជូនដំណឹង ១៣៣៤ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ (ពុំមាននៅលើបណ្តាញអ៊ិនធឺណិត)។

[42] ទ្រី ភាព គ្រុប គេហទំព័រផ្លូវការ "តំបន់សេដ្ឋកិច្ចពិសេស" Try Pheap Group Co., Ltd, 2018, http://trypheapgroup.com/?page=10

[43] ភូមិសង្គមថ្មី ភូមិកណ្តាល ភូមិឯកភាព យោងតាមរបាយការណ៍សង្ខេបស្តីពីផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន អិម ឌី អេស អេស អ៊ី ហ្សិត ក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧ របស់អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF) គណៈកម្មាធិការប្រព្រឹត្តកម្ម នៃអង្គការ-សមាគមន៍ការពារសិទ្ធិមនុស្ស កម្ពុជា (CHRAC) មជ្ឈមណ្ឌលអប់រំច្បាប់ សម្រាប់សហគមន៍ (CLEC) សមាគមការពារសិទ្ធិមនុស្ស អាដហុក (ADHOC) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) អង្គការសិទ្ធិមនុស្សលីកាដូ (LICADHO) ខេត្តពោធិ៍សាត់ (អាចស្វែងរកឯកសារនេះបានពីអង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា)។

បន្ថែមទៀតថា បន្ទាប់ពីមានជម្លោះដីធ្លីកើតឡើង មានការបែកបាក់ផ្ទៃក្នុងរបស់សហគមន៍ មានអំពើហិង្សាក្នុងគ្រួសារ ជួនកាលឈានដល់ការលែងលះគ្នា និងការរើសអើងពីសំណាក់អាជ្ញាធរ ព្រោះអាជ្ញាធរចោទពួកគាត់ជាគណបក្សប្រឆាំង ដោយសារតែពួកគេតែងតែធ្វើការទាមទារសិទ្ធិរបស់ពួកគាត់ ថែមទាំងប្រឈមនឹងបញ្ហាផ្លូវចិត្តជាច្រើនដូចជាភាពតានតឹង និងការធ្លាក់ទឹកចិត្ត។ កូនចៅនៅក្នុងក្រុមគ្រួសារជាច្រើនបានធ្វើចំណាកស្រុកទៅទីក្រុងភ្នំពេញ និងប្រទេសថៃ។ រីឯពួកគាត់មួយចំនួនទៀតបានខ្ចីប្រាក់ធនាគារដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ហើយបានក្លាយជាកូនបំណុល។

រីឯដំណោះស្រាយវិញ អាជ្ញាធរបានផ្តល់សំណងទឹកប្រាក់ ឬជាសម្បទានដីសង្គមកិច្ច ដល់សហគមន៍ដែលរងផលប៉ះពាល់។ ប្រជាពលរដ្ឋជាច្រើនបានរាយការណ៍ថា ពួកគាត់ត្រូវបង្ខំទទួលយកសំណងជាទឹកប្រាក់មិនសមរម្យ ឬសម្បទានដីសង្គមកិច្ច។ ជាងនេះទៅទៀតទីតាំងដីសម្បទានដីសង្គមកិច្ចនោះគឺស្ថិតនៅក្នុងតំបន់ដែលពោពេញទៅដោយគ្រាប់មីន។ អាជ្ញាធរបានចាប់ផ្តើមដំណើរការដោះមីន ប៉ុន្តែពុំទាន់មានពេលកំណត់ច្បាស់លាស់ទេ ថាតើពេលណាទើបការដោះមីននឹងត្រូវបញ្ចប់។ រហូតមកដល់បច្ចុប្បន្ននេះនៅមានប្រជាពលរដ្ឋចំនួន ១៧ គ្រួសារទៀតមិនទាន់ទទួលបានដំណោះស្រាយដែលពេញចិត្តក្នុងជម្លោះដីធ្លីនោះនៅឡើយទេ។

## **សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

ដូចដែលបានគូសបញ្ជាក់នៅក្នុងសលាកប័ត្រព័ត៌មាននេះ ខណៈដែលតំបន់សេដ្ឋកិច្ចពិសេសអាចមានផលវិជ្ជមានក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ប៉ុន្តែក៏មានផលប៉ះពាល់ធ្ងន់ធ្ងរផងដែរចំពោះសិទ្ធិរបស់សហគមន៍មូលដ្ឋាន ប្រសិនបើតំបន់សេដ្ឋកិច្ចទាំងនោះមិនត្រូវបានបង្កើតឡើង និងប្រតិបត្តិការដោយផ្សារភ្ជាប់នឹងការគោរពសិទ្ធិមនុស្សនោះទេ។

រាជរដ្ឋាភិបាលកម្ពុជាគួរដោះស្រាយបញ្ហាទាំងឡាយដូចបានពិពណ៌នាខាងលើ ជាពិសេស ម.ស.ម.ក សូមផ្តល់អនុសាសន៍ដូចខាងក្រោម ៖

១. បដិសេធការអនុញ្ញាតឱ្យបង្កើតតំបន់សេដ្ឋកិច្ចពិសេស លុះត្រាតែអាជ្ញាធរដែលពាក់ព័ន្ធបានអនុវត្តជំហានដូចខាងក្រោម ៖

១.១ ចូលរួមក្នុងការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយបុគ្គល និងសហគមន៍ ដែលរងផលប៉ះពាល់។ នៅទីណាដែលតំបន់សេដ្ឋកិច្ចពិសេសនឹងប៉ះពាល់ដល់សហគមន៍ជនជាតិដើមភាគតិចត្រូវធានាថា ពួកគាត់បានទទួលការយល់ព្រមដោយដោយពេញចិត្ត ដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ។

១.២ ទទួលយកមកពិចារណានូវការអនុវត្តសិទ្ធិមនុស្ស និងគោលនយោបាយរបស់វិនិយោគិនប្រកបដោយសក្តានុពល និងដកចេញវិនិយោគិនទាំងឡាយណាដែលមានកំណត់ត្រាមិនល្អ។

១.៣ អនុវត្តការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម ហើយលទ្ធផលនៃការវាយតម្លៃទាំងនោះគួរត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

២. ធ្វើកំណែទម្រង់របបច្បាប់គ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ដើម្បីឱ្យស្របតាមការអនុវត្តល្អបំផុត និងស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជាពិសេសការធានាការអនុវត្តច្បាប់ការងារ និងសិទ្ធិទទួលបានប្រាក់ឈ្នួលអប្បបរមានៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនៅទូទាំងប្រទេសកម្ពុជា។

៣. ធានាថាអនុក្រឹត្យត្រូវបានអនុម័តដើម្បីបង្កើតតំបន់សេដ្ឋកិច្ចពិសេស និងកំណត់ព្រំប្រទល់ច្បាស់លាស់នៃតំបន់នោះ និងដែលអាចស្វែងរកបានជាសាធារណៈ។

៤. ធានាឱ្យមានសេរីភាពខាងសមាគមត្រូវបានការពារក្នុងតំបន់សេដ្ឋកិច្ចពិសេសដែលរួមមាន៖ ធានាឱ្យតំណាងសហជីពអាចចូលទៅកាន់តំបន់សេដ្ឋកិច្ចពិសេស និងបំពេញតួនាទីរបស់ខ្លួនក្នុងនាមជាសមាជិកសហជីព និងការការពារសមាជិកសហជីព ឬអ្នកទាំងឡាយណាដែលស្នើសុំបង្កើត ឬចូលរួមសហជីព រួចផុតពីការរើសអើង និងការគំរាមកំហែង។

៥. បង្កើតយន្តការទទួលបណ្តឹងដោយឯករាជ្យ មិនលំអៀង និងមានប្រសិទ្ធិភាព ដើម្បីទទួល និងដោះស្រាយបណ្តឹងរបស់កម្មករនិយោជិត តំបន់សេដ្ឋកិច្ចពិសេស និងសហគមន៍មូលដ្ឋានដែលសិទ្ធិមនុស្សរបស់ពួកគេបានរងផលប៉ះពាល់អវិជ្ជមានដោយតំបន់សេដ្ឋកិច្ចពិសេស។

សំរាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក វណ្ណ សុផាត អ្នកសម្របសម្រួលគម្រោងធុរកិច្ចនិងសិទ្ធិមនុស្សរបស់ ម.ស.ម.ក តាមរយៈលេខទូរស័ព្ទ (៨៥៥) ១២ ៩៤១ ២០៦ ឬតាមរយៈអ៊ីម៉ែល vann.sophath@cchrcambodia.org

ចប់

BY NC SA